# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### កិច្ចព្រមព្រៀង

### ស្តីពី

### ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០២០

**រវាង**

ក្រុមហ៊ុន **ឃែនធើរេនអឺភែរឹល (ខេមបូឌា )** មានទីតាំងស្ថិតនៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យរាជធានីភ្នំពេញតំណាងដោយលោក CHOONG WEIPIAU ចាប់ពីពេលនេះតទៅហៅថា ភាគី "ក"។

**ជាមួយនឹង**

កម្មករនិយោជិតនៃក្រុមក្រុមហ៊ុន **ឃែនធើរេនអឺភែរឹល (ខេមបូឌា )** មានទីតាំងស្ថិតនៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញដែលតំណាងដោយ តំណាងកម្មករ ប្រតិភូបុគ្គលិក និង ថ្នាក់ដឹកនាំសហជីព ចាប់ពីពេលនេះតទៅហៅកាត់ថា ភាគី "ខ"។

**ដោយហេតុថា**

១- ***ដោយហេតុថា៖*** ភាគី"ក"ជួបការលំបាកផ្នែកសេដ្ឋកិច្ច ដោយសារមានការរីករាលដាលជាសកលនៃជំងឺឆ្លង COVID-19 ធ្វើអោយការបញ្ជាទិញថយចុះនិងមានការពន្យាពេលការ បេញទំនិញដែលនាំឲ្យមិនមានការងារឲ្យកម្មករនិយោជិតធ្វើគ្រប់គ្រាន់។

២- ***ដោយហេតុថា៖*** ភគី "ក" មានបំណងចង់ព្យួរកិច្ចសន្យាការងារ មានថិរៈវេលា ១ (មួយ)ខែ ។

៣- ***ដោយហេតុថា៖*** ភាគី "ក" និងភាគី "ខ" បានពិភាក្សាគ្នា និងបានព្រមព្រៀងគ្នារួចហើយ។



ព្រះរាជាណាចក្រកម្ពុជា CANTERAN APPAREL (CAMBODIA) CO.,LTD.

ក្រោយពីបានពិភាក្សាគ្នាមក ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោមៈ

**ប្រការ១ៈ ការព្រមព្រៀង**

១.១- ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងព្យួរកិច្ចសន្យាការងារ មានថិរវេលាចំនួន ១(មួយ) ខែ ដោយគិតចាប់ពីថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០២០។ ដែលមានកម្មករព្យួរ ចំនួន ១៦៣ នាក់ ស្រី ១១៥ នាក់ ក្នុងចំនោមចំនួនកម្មករនិយោជិតសរុប៩៩២ នាក់ ។

១.២- ការព្យួរការងារពាក់កណ្តាល ៥០ (ហាសិប) ភាគរយទៅតាមផ្នែកនិមួយៗ

១.៣-ភាគី(ក)ជាអ្នករៀបចំការព្យួរកិច្ចសន្យាការងារនេះតាមផ្នែកនៃសង្វាក់ផលិតកម្មរបស់ក្រុមហ៊ុន ។

១.៤-ភាគី(ខ)ត្រូវគោរពតាមការរៀបចំព្យួរកិច្ចសន្យាការងាររបស់ភាគី (ក)ក្នុងករណីមិនគោរពតាមការរៀបចំរបស់ភាគី (ក ) ទេរាល់ការបាត់បង់អត្ថប្រយោជន៍ផ្សេងៗភាគី (ក ) មិនទទួលខុសត្រូវឡើយ ។

១:៥-ភាគី(ក)ត្រូវបំពេញលេខអត្តសញ្ញាណប័ណ្ណ និងលេខទូរសព្ទ័អោយបានត្រឹមត្រូវតាមសេចក្តីណែនាំរបស់ក្រសួងការងារ ។

**ប្រការ២-ការផ្តល់ប្រាក់ឧបត្ថម្ភ**

២.១- ភាគី "ក" យល់ព្រមផ្តល់ប្រាប់ឧបត្ថម្ភដល់ភាគី "ខ" តាមសេចក្តីណែនាំរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវ: ( លេខ ០៤៥/២០ / ក.ប / សណនខល ) ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០២០ ។

**ប្រការ៣-របៀបបើកប្រាក់ឧបត្ថម្ភ**

៣.១-ភាគី "ក" នឹងបើកប្រាក់ឧបត្ថម្ភជូនភាគី "ខ" តាមសេចក្តីប្រកាសរបស់ក្រសួងការងារស្តីពីការបើកប្រាក់ឈ្នួលប្រចាំខែ(លើកទី១នៅថ្ងៃទី១៩និងលើកទី២នៅថ្ងៃទី៧ខែបន្ទាប់) នៅ វេលាម៉ោង ២.៣០(ពីរសាមសិប)នាទីរសៀលតាមខែនិមួយៗ ។

៣.២- ភាគី "ខ" នឹងទទួលប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលអនុវត្តនតាម (សេចក្តីណែនាំលេខ ០៤៥/២០ប.ក/ស.ណ.ន.ខ.ល )ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០២០ ។



ព្រះរាជាណាចក្រកម្ពុជា CANTERAN APPAREL (CAMBODIA) CO.,LTD.

**ប្រការ៤- អវសានប្បញ្ញត្តិ**

៤.១-ភាគីទាំងពីរបានអាននិងយល់ច្បាស់គ្រប់ប្រការដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះហើយភាគីទាំងពីរបានឯកភាពគ្នាចុះហត្ថលេខាដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។

៤.២- កិច្ចព្រមព្រៀងនេះធ្វើឡើងជាភាសាខ្មែរ ចំនួន០៣ច្បាប់ ដោយរក្សាទុកនៅ៖

-ភាគី "ក" ចំនួន ០១ (មួយ) ច្បាប់។

-ភាគី "ខ" ចំនួន ០១ (មួយ) ច្បាប់។

-ការិយាល័យមេធាវី ចំនួន ០១ (មួយ) ច្បាប់។

៤.៣កិច្ចព្រមព្រៀងនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខារបស់ភាគីទាំងពីរតទៅ។

៤.៤ ភាគីទាំងពីរព្រមព្រៀងចាត់ទុកជាមោឃៈនូវរាល់កិច្ចព្រមព្រៀងកន្លងមកទោះបីជាបានធ្វើជាលាយលក្ខអក្សរឬពាក្យសំដីក្តី។

**តំណាងភាគី "ក"**

CANTERAN APPAREL (CAMBODIA) CO.,LTD

CHOONG WEI MING

**តំណាងភាគី "ខ"**